# ឯកសារជំនួយស្មារតីរបស់កម្មវិធី អាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ស្តីពីសូចនាករសមិទ្ធកម្មសំខាន់ៗ ស្តីពីអំពើជួញដូរមនុស្ស

## កសាងមូលដ្ឋានភស្តុតាង សម្រាប់អនុវត្តអភិក្រមយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ក្នុងការអនុវត្តនីតិវិធីចំពោះសំណុំរឿងជួញដូរមនុស្ស ក្នុងតំបន់អាស៊ាន



Australian Aid | ASEAN-Australia Counter Trafficking

ខែមីនា ឆ្នាំ ២០២២

អ្នកនិពន្ធ ៖ Cate Sumner ទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធី ASEAN-ACT

សិទ្ធិអ្នកនិពន្ធសម្រាប់ឯកសារនេះទាំងមូល និងសម្រាប់គ្រប់ផ្នែកទាំងអស់នៃឯកសារនេះ គឺជាសិទ្ធិរបស់ក្រុមហ៊ុន Cardno និងមិនអាចយកទៅប្រើប្រាស់ លក់ ផ្ទេរ ចម្លង ឬផលិតឡើងវិញទាំងស្រុង ឬផ្នែកណាមួយទោះជាដោយវិធីណាក៏ដោយ ឬដោយប្រើប្រាស់ ឬក្នុងទម្រង់ជាប្រព័ន្ធផ្សព្វផ្សាយអ្វីមួយ ទៅឱ្យជនណាដែលពុំមានការព្រមព្រៀងពីក្រុមហ៊ុន Cardno។ ឯកសារនេះត្រូវបានផលិតដោយក្រុមហ៊ុន Cardno តែដើម្បីប្រយោជន៍ និងការប្រើប្រាស់របស់អតិថិជន ស្របតាមលក្ខខណ្ឌនៃការជួលឱ្យបំពេញការងារនេះតែប៉ុណ្ណោះ។ ក្រុមហ៊ុន Cardno មិន និងមិនត្រូវទទួលយកការទទួលខុសត្រូវអ្វីមួយចំពោះភាគីទី ៣ ដែលកើតឡើងដោយសារការប្រើប្រាស់ ឬការពឹងអាស្រ័យពីសំណាក់ភាគីទី ៣ លើខ្លឹមសារនៃឯកសារនេះឡើយ។

សេចក្តីបដិសេធ៖ រដ្ឋាភិបាលអូស្ត្រាលី ផ្តល់ថវិកាគាំទ្រសម្រាប់ការរៀបចំឯកសារនេះ តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនយល់ឃើញដែលលើកឡើងនៅក្នុងឯកសារនេះ គឺជាទស្សនយល់ឃើញរបស់អ្នកនិពន្ធតែឯងប៉ុណ្ណោះ និងមិនមែនជាទស្សនយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។

# ទិដ្ឋភាពទូទៅ

ការបោះពុម្ពផ្សាយប្រកបដោយតម្លាភាព នូវរបាយការណ៍ប្រចាំឆ្នាំថ្នាក់ជាតិស្តីពីអំពើជួញដូរមនុស្សរបស់ប្រទេសនីមួយៗ ជានាថា ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋរាប់រយស្ថាប័នក្នុងរដ្ឋជាសមាជិកអាស៊ាន ដែលធ្វើការងារដើម្បីឈានទៅសម្រេចគោលដៅនៃអនុសញ្ញានេះ និងដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះ ដូចជា ជម្រក ជំនួយផ្នែកច្បាប់ ការគាំទ្រផ្នែកវេជ្ជសាស្រ្ត និងការផ្តល់ប្រឹក្សា មានព័ត៌មានដូចគ្នាសម្រាប់រៀបចំ និងកែលម្អការផ្តល់សេវារបស់ខ្លួន។

គោលដៅ គឺដើម្បីបញ្ចៀសការប្រើប្រាស់អភិក្រមប្រមូលទិន្នន័យដែលមានលក្ខណៈបែកខ្ញែកគ្នាទៅតាមស្ថាប័ននីមួយៗ ដែលមិនផ្តល់នូវរូបភាពពេញលេញពីសកម្មភាពអនុវត្តអនុសញ្ញានេះនៅតាមប្រទេសនីមួយៗ។

ឯកសារជំនួយស្មារតីនេះផ្តោតសំខាន់លើមន្ត្រី ដែលកំពុងធ្វើការក្នុងស្ថាប័នជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលទទួលខុសត្រូវលើការចងក្រងរបាយការណ៍ប្រចាំឆ្នាំស្តីពីអំពើជួញដូរមនុស្ស។

# ហេតុអ្វីបានជាទិន្នន័យមានសារៈសំខាន់ចំពោះ ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស?

កាលពីខែវិច្ឆិកា ឆ្នាំ ០២១៥ រដ្ឋជាសមាជិកអាស៊ានទាំង ១០ បានចុះហត្ថលេខាលើ<u>អនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ហៅកាត់ថា អនុសញ្ញា)</u>។ អនុសញ្ញានេះចែងពីកាតព្វកិច្ចតាមច្បាប់ ដើម្បីជួយដល់រដ្ឋជាសមាជិកអាស៊ានក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមជាច្រើន ដែលកំពុងកើតមាននៅតាមប្រទេសរបស់ពួកគេ បង្ហាញពីអាទិភាព និងយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។



ការបោះពុម្ពផ្សាយទិន្នន័យជួញដូរមនុស្ស ដែលបង្ហាញពីនិន្នាការ ៣ ទៅ ៥ ឆ្នាំ រឹតតែមានតម្លៃទៅទៀត ត្បិតវាអនុញ្ញាតឱ្យរដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការពិចារណា ថាតើកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងនេះអាចរួមចំណែកដល់ការសម្រេចលទ្ធផលដោយរបៀបណា និងបង្ហាញពីជំហានបន្តបន្ទាប់ដែលចាំបាច់ត្រូវអនុវត្ត។

នៅក្នុងបុព្វកថានៃអនុសញ្ញានេះ រដ្ឋជាសមាជិកអាស៊ាន បានលើកឡើងពីតម្រូវការដើម្បី៖

> *ដើម្បីបង្កើតលិខិតឧបករណ៍ថ្នាក់តំបន់មួយសម្រាប់ធ្វើការ ជាពិសេសប្រឆាំងការជួញដូរមនុស្សដែលជាក្រមខ័ណ្ឌច្បាប់ សម្រាប់ធ្វើសកម្មភាពនៅថ្នាក់តំបន់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមទាំងកិច្ចការពារ និងការជួយជនរងគ្រោះដោយការជួញដូរមនុស្សផងដែរ។*

ការអនុវត្តអនុសញ្ញានេះ ពឹងអាស្រ័យលើការប្រមូល ការវិភាគ និងការបោះពុម្ពផ្សាយទិន្នន័យករណីជួញដូរមនុស្សនៅតាមប្រទេស ដើម្បីកំណត់ថាតើមានការអនុវត្តតាមកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញានេះដែរឬទេ ក៏ដូចជា ចែករំលែកអភិក្រមដែលត្រូវបានប្រើប្រាស់ ដើម្បីប្រយុទ្ធនឹងករណីជួញដូរមនុស្សនៅក្នុងតំបន់អាស៊ានទាំងមូល និងឆ្លុះបញ្ចាំងលើវិធីសាស្ត្រដែលអាចប្រើប្រាស់ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

ការបោះពុម្ពផ្សាយប្រកបដោយតម្លាភាពនៃរបាយការណ៍ប្រចាំឆ្នាំ អំពីករណីជួញដូរមនុស្សក្នុងតំបន់អាស៊ាន បង្ហាញពីការប្តេជ្ញាចិត្តនៃប្រទេសទាំងនោះ ក្នុងការសម្រេចបំណងប្រាថ្នានៅថ្នាក់តំបន់ ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការប្រឆាំងការជួញដូរមនុស្ស។

**ប្រសិនបើពុំមានទិន្នន័យនោះទេ គេពិបាកនឹងប្រាប់៖**



ថាតើថវិកាដែលរដ្ឋាភិបាលបែងចែក សម្រាប់ការស៊ើបអង្កេត និងការចោទប្រកាន់ និងផ្តន្ទាទោស ការជួញដូរមនុស្សកំពុងសម្រេចបាននូវផលជះយ៉ាងដូចម្តេចខ្លះ



ថាតើនិន្នាការករណីជួញដូរមនុស្ស មានការប្រែប្រួលនៅក្នុងប្រទេស/តំបន់ដែរឬទេ



តើចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្សអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះនិន្នាការថ្មីៗនៃការជួញដូរមនុស្ស

# ហេតុអ្វីបានជាទិន្នន័យមានសារៈសំខាន់សម្រាប់អនុវត្តអភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ?

អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)
បញ្ចូលបញ្ញត្តិសំខាន់ៗស្តីពីការគាំទ្រដល់ជនរងគ្រោះ

**កម្មវិធី ASEAN -ACT** កំពុងធ្វើការងារជាមួយរដ្ឋជាសមាជិក ដើម្បីអនុវត្តបញ្ញត្តិនៃអនុសញ្ញា ACTIP ដែលបានកំណត់នូវ**សូចនាករចំនួន ៨ ដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។**

8

គេអាចសង្កេតឃើញនូវភស្តុតាងដែលបង្ហាញថាបញ្ញត្តិនៃអនុសញ្ញា ACTIP កំពុងត្រូវបានអនុវត្តនៅតាមរដ្ឋជាសមាជិកអាស៊ាន ដូចជា **តាមរយៈរបាយការណ៍ស្តីពី KPIs ទិន្នន័យចំនួន ២២ ដែលត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់រដ្ឋជាសមាជិកទាំងនោះ**

22

តម្លាភាពនៃរបាយការណ៍ជាតិស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងអភិក្រមដែលកំពុងត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌអាស៊ាន នឹងជួយពង្រឹងដល់ការអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញានេះ ក៏ដូចជាការគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

# តើជនរងគ្រោះដោយអំពើជួញដូរមនុស្សចាំបាច់ត្រូវដឹងអ្វីខ្លះ ប្រសិនបើពួកគេត្រូវធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ក្នុងការចូលខ្លួនធ្វើជាសាក្សី?

ការផ្តន្ទាទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ពឹងអាស្រ័យយ៉ាងច្រើនលើការត្រៀមខ្លួនរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីធ្វើជាសាក្សី ក្នុងនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាបង្ហាញភស្តុតាងរំលឹកឡើងវិញពីអ្វីដែលបានកើតឡើងចំពោះពួកគេ។ បទពិសោធន៍នេះអាចបង្កជាការប៉ះទង្គិចផ្លូវចិត្ត ហើយជនរងគ្រោះត្រូវការព័ត៌មានត្រឹមត្រូវ ដើម្បីធ្វើការសម្រេចចិត្តថាតើពួកគេចង់ធ្វើជាសាក្សីដែរឬទេ។

ប្រសិនបើពុំមានទិន្នន័យអំពីករណីជួញដូរមនុស្សពីតាមប្រទេសនានា ដែលពន្យល់ពីផលវិបាកដែលកើតមានចំពោះជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងជនរងគ្រោះ ក៏ដូចជាអំពីការគាំទ្រដែលផ្តល់ដល់ជនរងគ្រោះ ក្នុងអំឡុងនីតិវិធីចោទប្រកាន់ និងផ្តន្ទាទោសករណីជួញដូរមនុស្សនោះទេ ជនរងគ្រោះមិនអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវបែបនេះឡើយ។

ការបង្ហាញពីចំណាត់ការដែលត្រូវបានអនុវត្តចំពោះករណីជួញដូរមនុស្សនៅក្នុងតំបន់អាស៊ាន ក៏ដូចជាការប្រតិបត្តិមកលើជនរងគ្រោះដែលជាសាក្សីនៅក្នុងសំណុំរឿងទាំងនេះ ក៏នឹងជួយកែលម្អការប្រតិបត្តិមកលើជនរងគ្រោះ ក៏ដូចជាធ្វើឱ្យពួកគេទទួលបានលទ្ធផលកាន់តែប្រសើរ។ នេះអាចជំរុញឱ្យជនរងគ្រោះបន្ថែមទៀតផ្តល់សក្ខីកម្មក្នុងសំណុំរឿងជួញដូរមនុស្សនាពេលអនាគត។

## ជនរងគ្រោះនៃអំពើជួញដូរមនុស្សចង់ដឹង៖



# អភិក្រមយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ក្នុងការអនុវត្តនីតិវិធី ចំពោះសំណុំរឿងជួញដូរមនុស្ស៖ សូចនាករសមិទ្ធកម្មសំខាន់ៗចំនួន ២២ ពាក់ព័ន្ធនឹងទិន្នន័យ

រដ្ឋជាសមាជិកអាស៊ានបានចាត់ទុកការយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ក្នុងសំណុំរឿងជួញដូរមនុស្ស ថាជាអាទិភាពមួយ ក្នុងអនុសញ្ញានេះ។

ប្រទេសជាសមាជិកអាស៊ានភាគច្រើន បានប្រមូលទិន្នន័យជាច្រើនរួចទៅហើយអំពីការជួញដូរមនុស្ស។ ប៉ុន្តែ រដ្ឋជាសមាជិកអាស៊ានអាចពិចារណា បង្ហាញសូចនាករទិន្នន័យចំនួន ២២ ដូចខាងក្រោម ក្នុងរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សក្នុងប្រទេសរបស់ខ្លួន។ រដ្ឋជាសមាជិកអាស៊ានភាគច្រើនកំពុងប្រមូលទិន្នន័យនេះរួចទៅហើយ ហើយការបញ្ចូលទិន្នន័យនេះទៅក្នុងរបាយការណ៍ជាតិប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស នឹងបង្ហាញឱ្យឃើញថាតើរដ្ឋជាសមាជិកកំពុងអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចចែងក្នុងអនុសញ្ញានេះក្នុងកម្រិតណា ក៏ដូចជាបង្ហាញពីបទពិសោធន៍របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលកំពុងចូលរួមអនុវត្តនីតិវិធីទាំងនេះ ប្រសិនបើពួកគេសម្រេចចិត្តធ្វើជាសាក្សីក្នុងនីតិវិធីព្រហ្មទណ្ឌ ឬដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណង។

KPIs ទិន្នន័យខាងក្រោមគាំទ្រដល់*អនុសាសន៍ស្តីពីគោលការណ៍ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស* ដែលត្រូវបានរៀបចំឡើងដោយឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក៏ដូចជាសូចនាករចំនួន ៨ **ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងគោលការណ៍ណែនាំស្តីពីការអនុវត្តគោលការណ៍ណែនាំទាំងនេះ** ដែលត្រូវបានរៀបចំឡើងដោយកម្មវិធី ASEAN-ACT។





# សូចនាករ ១-៥




**ប្រធានបទ៖ ទិន្នន័យស្ដីពីការគ្រប់គ្រងករណី ដែលបានពីនគរបាល អយ្យការ និងតុលាការ**

## ហេតុអ្វីបានជាទិន្នន័យនេះមានសារៈសំខាន់សម្រាប់អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ?

ទិន្នន័យស្ដីពីការចោទប្រកាន់ទោសអំពើជួញដូរមនុស្ស ជាពិសេសនៅពេលបង្ហាញក្នុងទម្រង់ជានិន្នាការ ៣-៥ ឆ្នាំ បង្ហាញឱ្យឃើញ ថាតើករណីមួយត្រូវការពេលយូរប៉ុណ្ណា ទើបនាំឱ្យមានការចោទប្រកាន់ទោស ចាប់ពីដំណាក់កាលរបាយការណ៍របស់នគរបាល រហូតដល់ការបញ្ចប់សំណុំរឿងក្នុងតុលាការ ថាតើមានការកកស្ទះសំណុំរឿងជួញដូរមនុស្សនៅក្នុងតុលាការដែរឬទេ និងថាតើមានការប្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿងជួញដូរមនុស្សជាច្រើនករណីទៅកាន់តុលាការនៅថ្នាក់ខ្ពស់ដែរឬទេ។

រយៈពេលនៃចំណាត់ការលើសំណុំរឿងមួយ និងលទ្ធភាពដែលការសម្រេចរបស់តុលាការត្រូវបានប្ដឹងឧទ្ធរណ៍ទៅកាន់តុលាការនៅកម្រិតខ្ពស់ជាង គឺជាកត្តាសំខាន់ដែលជនរងគ្រោះត្រូវធ្វើការពិចារណា នៅពេលពួកគេធ្វើការសម្រេចចិត្ត ថាតើត្រូវធ្វើជាសាក្សីក្នុងករណីជួញដូរមនុស្សដែរឬទេ។

**សូចនាករសមិទ្ធកម្មសំខាន់ៗពាក់ព័ន្ធនឹងទិន្នន័យទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ១២ និង ១៦ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។**



# សូចនាករ ៦-៩

៦ លទ្ធផលនៃសំណុំរឿងកាត់ឱ្យជាប់ទោស ឬកាត់ឱ្យរួចខ្លួន

៧ លទ្ធផលនៃសំណុំរឿងចុងចោទត្រូវបានផ្តន្ទាទោស

៨ លទ្ធផលនៃសំណុំរឿងសំណងជំងឺចិត្ត សំណងបដិទាន សំណងជួសជុលការខូចខាត

៩ លទ្ធផលនៃសំណុំរឿងសំណងជំងឺចិត្ត សំណងបដិទាន សំណងជួសជុលការខូចខាត

## ប្រធានបទ៖ លទ្ធផលសម្រាប់ជនរងគ្រោះ

### ហេតុអ្វីបានជាទិន្នន័យនេះមានសារៈសំខាន់សម្រាប់អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ?

សូចនាករទិន្នន័យលទ្ធផលនៃសំណុំរឿងជួញដូរមនុស្ស បង្ហាញពីចំនួនសំណុំរឿងដែលត្រូវបានកត់ត្រាថាមានការផ្តន្ទាទោស ឬការទម្លាក់បទចោទ និងចំនួនសំណុំរឿងដែលមានការបញ្ជាឱ្យមានការផ្តល់សំណងជំងឺចិត្ត/សំណងបដិទាន/សំណងជួសជុលការខូចខាត ក៏ដូចជាសំណុំរឿងដែលជនរងគ្រោះពិតជាបានទទួលសំណងពិតប្រាកដ អាចពីមូលនិធិជាតិផ្តល់សំណង ឬសំណងបដិទាន/សំណងជួសជុលការខូចខាតពីជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។

លទ្ធភាពដែលការចោទប្រកាន់ និងផ្តន្ទាទោសក្នុងសំណុំរឿងជួញដូរមនុស្សបានទទួលជោគជ័យ និងថាតើតុលាការតែងបញ្ជាឱ្យមានការផ្តល់សំណងជំងឺចិត្ត សំណងបដិទាន ឬសំណងជួសជុលការខូចខាត គឺជាកត្តាដ៏សំខាន់មួយ ដែលជនរងគ្រោះយកមកធ្វើការពិចារណា នៅពេលធ្វើការសម្រេចចិត្ត ថាតើពួកគេនឹងធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្សដែរឬទេ។

KPIs ពាក់ព័ន្ធនឹងទិន្នន័យទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលត្រូវបានចែងនៅក្នុងមាត្រា ១៤ និង ១៦ នៃអនុសញ្ញាអាស៊ានស្តីពីការជួញដូរមនុស្ស។



# សូចនាករ ១០-១២

| | | |
|---|---|---|
| ១០ ជនរងគ្រោះទទួលបានការគាំទ្រដល់ជនរងគ្រោះ ជំនួយផ្លូវច្បាប់ | ១១ ការគាំទ្រដល់ជនរងគ្រោះ - ការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូ | ១២ ការគាំទ្រដល់ជនរងគ្រោះ - យន្តការដាក់ពាក្យបណ្តឹងជាសាធារណៈ |

## ប្រធានបទ៖ ការគាំទ្រដល់ជនរងគ្រោះ

### ហេតុអ្វីបានជាទិន្នន័យនេះមានសារៈសំខាន់ សម្រាប់អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ?

សូចនាករទិន្នន័យករណីជួញដូរមនុស្សទាំងនេះ បង្ហាញថាតើក្នុងសំណុំរឿងជួញដូរមនុស្សប៉ុន្មានករណីដែលជនរងគ្រោះបានទទួលជំនួយផ្លូវច្បាប់ ដែលផ្តោតលើសិទ្ធិរបស់ពួកគេ (ការផ្តល់ជំនួយនេះ អាចកើតឡើងនៅដំណាក់កាលផ្សេងៗនៃដំណើរការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ) ថាតើជនរងគ្រោះអាចថតការផ្តល់សក្ខីកម្មរបស់ខ្លួនមុនពេលនីតិវិធីជំនុំជម្រះ និងថាតើមានដំណើរការដែលមានភាពច្បាស់លាស់សម្រាប់ដាក់ពាក្យបណ្តឹង ដែលបង្ហាញពីការប្រតិបត្តិដែលជនរងគ្រោះបានទទួល នៅដំណាក់កាលនានា ក្នុងដំណើរការអនុវត្តចំណាត់ការលើសំណុំរឿងជួញដូរមនុស្ស។

សំណុំទិន្នន័យនីមួយៗក្នុងចំណោមសំណុំទិន្នន័យទាំងនេះ មានសារៈសំខាន់ ដើម្បីជួយឱ្យជនរងគ្រោះអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ថាតើពួកគេចង់ធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្សដែរឬទេ។ ការផ្តល់ជំនួយផ្លូវច្បាប់ និងលទ្ធភាពរបស់សាក្សីក្នុងការថតទុកការផ្តល់សក្ខីកម្មរបស់ខ្លួនជាមុន គឺជាវិធី ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្ត ដែលជនរងគ្រោះដោយអំពើជួញដូរមនុស្សតែងទទួលរង។ ដំបូន្មានដែលផ្តល់ដល់ជនរងគ្រោះអំពីយន្តការចាត់ការលើបណ្តឹងរបស់សាធារណៈជន បង្ហាញឱ្យឃើញថាមានស្តង់ដារស្តីពីការប្រតិបត្តិចំពោះជនរងគ្រោះ ដែលគួរបន្តអនុវត្តប្រសិនបើជនរងគ្រោះសម្រេចចិត្តធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្ស។

ព័ត៌មានបន្ថែមអំពីរបៀបអនុវត្តសូចនាករដែលផ្តោតលើការគាំទ្រដល់ជនរងគ្រោះ អាចរកបានក្នុងគោលការណ៍ណែនាំស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។

KPIs ពាក់ព័ន្ធនឹងទិន្នន័យទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលត្រូវបានចែងនៅក្នុងមាត្រា ១១ និង ១៤ នៃអនុសញ្ញាអាស៊ានស្តីពីការជួញដូរមនុស្ស។

# សូចនាករ ១៣ - ១៦

**១៣** ទិន្នន័យអំពីប្រភេទអំពើជួញដូរមនុស្ស

**១៤** ទិន្នន័យបែងចែកតាមភេទ

**១៥** ទិន្នន័យបែងចែកតាមអាយុ

**១៦** ទិន្នន័យបែងចែកតាមពិការភាព

## ប្រធានបទ៖ ទម្រង់នៃការជួញដូរមនុស្ស និងទិន្នន័យបែងចែកតាមប្រភេទជនរងគ្រោះ

### ហេតុអ្វីបានជាទិន្នន័យនេះមានសារៈសំខាន់សម្រាប់អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ?

ការប្រមូលទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព មានសារៈសំខាន់ ដើម្បីឱ្យគេយល់ថាតើជនរងគ្រោះជានរណា និងថាតើពួកគេត្រូវការការគាំទ្រប្រភេទអ្វីខ្លះ។

ដោយប្រើប្រាស់សំណួរបំពេញស្ដីពីការបំពេញមុខងារ របស់ក្រុមវ៉ាស៊ីងតោន គេអាចប្រាប់ទៅតុលាការ ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អំពីជំនួយជាក់លាក់ ដែលជនមានពិការភាពត្រូវការ។

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកការជួញដូរមនុស្ស បានលើកឡើងពីសារៈសំខាន់នៃការប្រមូលទិន្នន័យអំពីស្ថានភាពពិការភាព នៅក្នុងបទអន្តរាគមន៍ដែលធ្វើឡើងនៅក្នុងសម័យប្រជុំលើកទី ២៤ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ៖

*ភាពប្រសព្វគ្នារវាងពិការភាព និងការជួញដូរមនុស្ស គឺជាបញ្ហា ដែលកន្លងមក មិនត្រូវបានទទួលការយកចិត្តទុកដាក់ នៅក្នុងច្បាប់អន្តរជាតិ គោលនយោបាយ និងការអនុវត្តដែលពាក់ព័ន្ធនឹងការជួញដូរមនុស្សឡើយ។ ភាពខ្វះចន្លោះនេះ គួរទទួលបានការឆ្លើយតបជាបន្ទាន់។ មានការបែងចែកទិន្នន័យតាមប្រភេទតិចតួចប៉ុណ្ណោះ អំពីបទពិសោធន៍ដែលជនមានពិការភាពមាន ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ឬប្រេវ៉ាឡង់នៃការកេងប្រវ័ញ្ចន៍ក្នុងទម្រង់ណាមួយ។ ចំណុចនេះ នាំឱ្យមានការមើលមិនឃើញ ក៏ដូចជាការខ្វះចំណេះដឹង និងការអនុវត្តល្អនានា។*

គេគួរពិចារណាប្រើប្រាស់សំណុំទិន្នន័យដែលបានពីការប្រើសំណួរបំពេញរបស់ក្រុមវ៉ាស៊ីងតោន នៅពេលធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលសំណួរទាំងនេះត្រូវបានប្រើប្រាស់ទូទាំងសកលលោកក្នុងទិន្នន័យជំរឿន និងទិន្នន័យដទៃទៀតរបស់ការិយាល័យស្ថិតិ ដូចជា៖

- តើអ្នកពិបាកក្នុងការមើលដែរឬទេ?
- តើអ្នកពិបាកក្នុងការស្ដាប់ដែរឬទេ?
- តើអ្នកពិបាកក្នុងការដើរ ឬផ្លាស់ទីដែរឬទេ?
- តើអ្នកពិបាកក្នុងការយល់ ឬផ្ចង់អារម្មណ៍ដែរឬទេ?
- តើអ្នកមានការពិបាក ដើម្បីឱ្យមនុស្សដទៃទៀតយល់ពីអ្នកដែរឬទេ?

ព័ត៌មានបន្ថែមអំពីរបៀបអនុវត្តសូចនាករដែលផ្ដោតលើការគាំទ្រដល់ជនរងគ្រោះ អាចរកបានក្នុងគោលការណ៍ណែនាំស្ដីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។

KPIs ពាក់ព័ន្ធនឹងទិន្នន័យទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលត្រូវបានចែងនៅក្នុងមាត្រា ៥, ១២, ១៤ និង ១៦ នៃអនុសញ្ញាអាស៊ានស្ដីពីការជួញដូរមនុស្ស។



# សូចនាករ ១៧ -២ ២

- ១៧ របាយការប្រចាំឆ្នាំស្តីពីករណីជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ
- ១៨ របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ ទិន្នន័យ និន្នាការ ៣ ទៅ ៥ ឆ្នាំ
- ១៩ របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស៖ កិច្ចសហការក្នុងប្រទេស និងថ្នាក់តំបន់
- ២០ របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស៖ មន្ត្រីដែលសមគំនិត
- ២១ ទីតាំងផ្តល់ព័ត៌មានអំពីសេវាគាំទ្រ និងផ្តល់ជំនួយសម្រាប់ករណីជួញដូរមនុស្ស
- ២២ ការសម្រេចចិត្តរបស់តុលាការក្នុងសំណុំរឿងជួញដូរមនុស្សត្រូវបានរក្សាអនាមិកភាព និងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ

ប្រធានបទ៖ តម្លាភាពនៃទិន្នន័យជួញដូរមនុស្ស ដើម្បីបង្កើនការយល់ដឹងដល់សាធារណៈជន ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ដែលកំពុងធ្វើការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

## ហេតុអ្វីបានជាទិន្នន័យនេះមានសារៈសំខាន់សម្រាប់អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ?

សូចនាករទិន្នន័យជួញដូរមនុស្សទាំងនេះ មានសារៈសំខាន់ ត្បិតអនុសញ្ញា ACTIP គឺជាអនុសញ្ញាថ្នាក់តំបន់ ដែលតម្រូវឱ្យមានការចែករំលែកទិន្នន័យសំខាន់ៗអំពីការជួញដូរមនុស្ស ដើម្បីធានាឱ្យមានការសម្រេចគោលដៅនៃអនុសញ្ញានេះ។ គេរំពឹងថាការបោះពុម្ពផ្សាយទិន្នន័យនិន្នាការ ៣ ទៅ ៥ ឆ្នាំឱ្យបានទាន់ពេលវេលានៅចុងឆ្នាំនីមួយៗ នឹងនាំឱ្យមានការផ្តល់ព័ត៌មានកាន់តែប្រសើរដល់ស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងតុលាការជាដៃគូរាប់រយស្ថាប័ន ដែលកំពុងចូលរួមអនុវត្តអនុសញ្ញា ACTIP នេះ។

ព័ត៌មានបន្ថែមអំពីរបៀបអនុវត្តសូចនាករដែលផ្តោតលើការគាំទ្រដល់ជនរងគ្រោះ អាចរកបានក្នុងគោលការណ៍ណែនាំស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។

KPIs ពាក់ព័ន្ធនឹងទិន្នន័យទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលត្រូវបានចែងនៅក្នុងមាត្រា ៨ និង ១១-១៦ នៃអនុសញ្ញាអាស៊ានស្តីពីការជួញដូរមនុស្ស។

# ការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សរបស់ប្រជាជាតិអាស៊ានមានសារៈសំខាន់សម្រាប់

### រដ្ឋជាសមាជិកអាស៊ាន

ដែលបានចុះហត្ថលេខាលើអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារក្នុងឆ្នាំ ២០១៥

ត្បិតរដ្ឋទាំងនេះប្តេជ្ញាសហការគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

ការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សកសាងនូវមូលដ្ឋានភស្តុតាងសម្រាប់ធ្វើការវាយតម្លៃ ថាតើការងាររបស់ស្ថាប័នទាំងនេះនាំមកនូវផលជះដែរឬទេ។

### ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

ដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះ ដូចជា ជម្រកសុវត្ថិភាព ជំនួយផ្លូវច្បាប់ សេវាវេជ្ជសាស្ត្រ និងការផ្តល់ប្រឹក្សាជាដើម

ត្បិតស្ថាប័នទាំងនេះរួមចំណែកដល់ការប្រមូលន និងវិភាគទិន្នន័យជួញដូរមនុស្ស ដើម្បីផ្តល់សេវានានាឱ្យមានប្រសិទ្ធភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

### ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ព្រោះថាជនរងគ្រោះទាំងនេះត្រូវការព័ត៌មាន ដើម្បីធ្វើការសម្រេចចិត្ត ថាតើពួកគេត្រូវផ្តល់ភស្តុតាងក្នុងសំណុំរឿងជួញដូរមនុស្សដែរឬទេ។

### ស្ថាប័នយុត្តិធម៌នៅថ្នាក់ជាតិ

ដូចជានគរបាល អយ្យការ និងតុលាការជាដើម

ត្បិតស្ថាប័នទាំងនេះពឹងអាស្រ័យលើសាក្សី និងជនរងគ្រោះ ដើម្បីផ្តល់ភស្តុតាងក្នុងសំណុំរឿងជួញដូរមនុស្ស។

ព័ត៌មានបន្ថែមអំពីសូចនាករនីមួយៗក្នុងចំណោមសូចនាករទិន្នន័យសំខាន់ៗ អំពីការជួញដូរមនុស្សទាំង ២២ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី ១ រួមទាំងព័ត៌មានអំពីវិធីសាស្ត្រដែលរដ្ឋជាសមាជិកអាស៊ានដទៃទៀតប្រើប្រាស់ ដើម្បីរាយការណ៍ពីការបំពេញតាមកាតព្វកិច្ចទាំងនេះផងដែរ។

ឯកសារក្នុងទម្រង់ excel ដែលបង្ហាញពីទម្រង់ដែលគេអាចប្រើប្រាស់ ដើម្បីបង្ហាញទិន្នន័យរយៈពេលពី ៣ ទៅ ៥ ឆ្នាំ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២។

**នៅជួរមុខ៖ ការអនុវត្តតាម ការអនុវត្តល្អក្នុងការប្រមូលទិន្នន័យអំពីការជួញដូរមនុស្ស** គឺជាសៀវភៅណែនាំលម្អិត អំពីគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូលទិន្នន័យអំពីការជួញដូរមនុស្ស ដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថាន Nexus Institute កាលពីឆ្នាំ ២០១៩ និងជាសៀវភៅជំនួយស្មារតីដ៏មានតម្លៃសម្រាប់ប្រទេសនានា ដែលមានបំណងចង់បានការណែនាំជាជំហានៗ អំពីរបៀបប្រមូលទិន្នន័យ និងរបៀបបកស្រាយទិន្នន័យអំពីការជួញដូរមនុស្ស។

KPIs ទិន្នន័យទាំង ២២ គាំទ្រដល់សូចនាករដែលយកចិត្តទុកដាក់ចំពោះយេនឌ័រទាំង ៨ និងគោលការណ៍ណែនាំស្តីពីការអនុវត្តសូចនាករទាំងនេះ ដែលត្រូវបានរៀបចំឡើងដោយកម្មវិធី ASEAN -ACT។



ផតថលមជ្ឈមណ្ឌលភាពជាដៃគូ (Partnership Hub) របស់កម្មវិធី ASEAN-ACT (aseanactpartnershiphub.com) ផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សរបស់រដ្ឋជាសមាជិកអាស៊ាន ហើយរបាយការណ៍ទាំងនេះផ្តល់នូវព័ត៌មានដ៏មានតម្លៃអំពីវិធីសាស្ត្រដែលប្រទេសដទៃទៀតប្រើប្រាស់ ដើម្បីប្រមូល និងផ្សព្វផ្សាយទិន្នន័យការជួញដូរមនុស្សរបស់ខ្លួន។

បច្ចុប្បន្ននេះអ្នកអាចឃើញរបាយការណ៍ជាតស្តីពីការជួញដូរមនុស្ស ពីរដ្ឋជាសមាជិកអាស៊ានខាងក្រោមលើផតថលនេះ សូមចុចនៅត្រង់នេះ៖


កម្ពុជា


ឥណ្ឌូនេស៊ី


ហ្វីលីពីន


ថៃ



# ឧបសម្ព័ន្ធទី ១

ការអនុវត្តអភិក្រមយកចិត្តទុកដាក់ចំពោះជន
រងគ្រោះ ក្នុងការអនុវត្តនីតិវិធីចំពោះសំណុំរឿង
ជួញដូរមនុស្ស៖ សូចនាករសមិទ្ធកម្មទិន្នន័យ
សំខាន់ៗទាំង ២២



# សូចនាករទី ១៖ របាយការណ៍ស្តីពីករណីជួញដូរមនុស្សរបស់នគរបាល

របាយការណ៍ពីចំនួនករណីជួញដូរមនុស្សដែលត្រូវបានប៉ូលីសស៊ើបអង្កេត/របាយការណ៍ ក្នុងឆ្នាំរបាយការណ៍។




ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

តារាងទី ១៖ ចំនួនសំណុំរឿងជួញដូរមនុស្សដែលត្រូវបានផ្តួចផ្តើមចងក្រង

| ឆ្នាំ | សរុប | ប្រភេទនៃសកម្មភាពជួញដូរមនុស្ស | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | អំពើពេស្យាចារ | រូបភាពអាសអាភាស | ការធ្វើអាជីវកម្មផ្លូវភេទ | អំពើទាសភាព | ការបង្ខំឱ្យសុំទាន | ពលកម្ម បង្ខំជាទូទៅ | ពលកម្មបង្ខំនៅក្នុងវិស័យនេសាទ | ការជម្រិតទារប្រាក់/ផ្សេងទៀត |
| ២០១៦ | ៣៣៣ | ២៤៤ | ៣ | - | - | ៨ | ៣២ | ៤៣ | ៣ |
| ២០១៧ | ៣០២ | ២៤៦ | ៧ | ២ | - | ២៦ | ១៤ | ៧ | - |
| ២០១៨ | ៣០៤ | ២៤៩ | ៤ | ៥ | - | ៨ | ២៩ | ៦ | ៣ |
| ២០១៩ | ២៨៨ | ១៥៨ | ១៥ | ១២ | ៣៣ | ៩ | ៣១ | ៤ | ២៦ |
| ២០២០ | ១៣១ | ៩៥ | ១៦ | ៦ | ០ | ២ | ៩ + (២) | ១ | ០ |

សម្គាល់៖ ចំនួននៅក្នុងវង់ក្រចក គឺជាករណីពលកម្មដោយបង្ខំ ឬករណីបង្ខំឱ្យផ្តល់សេវា ដែលជាបទល្មើសក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស។

# សូចនាករទី ២៖ របាយការណ៍ស្តីពីករណីជួញដូរមនុស្សរបស់អយ្យការ

របាយការណ៍ពីចំនួននៃការចេញដីកាកោះ/ការចោទប្រកាន់ករណីជួញដូរមនុស្សដែលត្រូវបានចេញនៅក្នុងឆ្នាំរបាយការណ៍។




ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

**១) វឌ្ឍនភាពនៃការពិនិត្យពិចារណាលើករណីជួញដូរមនុស្សពីព្រះរាជអាជ្ញា**

ក្នុងចំណោមករណីជួញដូរមនុស្សសុរប ២៤១ ករណីដែលអគ្គអយ្យការបានទទួលកាលពីឆ្នាំ ២០២០ មានករណីចំនួន ២២៥ ដែលជនសង្ស័យត្រូវបានឃាត់ខ្លួន ហើយ ១៦ ករណីជនសង្ស័យបានរត់គេចខ្លួន។ ព្រះរាជអាជ្ញាបានបញ្ចប់ការពិនិត្យពិចារណាលើសំណុំរឿងចំនួន ២៣៨ ករណី (ស្មើនឹង ៩៨,៨%) ដែលក្នុងនោះ ២១៣ ករណីត្រូវបានបញ្ជូនទៅកាន់តុលាការ។ បច្ចុប្បន្នសំណុំរឿងចំនួន ៦ ករណីដែលក្នុងនោះ ២ ករណីពីឆ្នាំ ២០១៩ និង ១ ករណីពីឆ្នាំ ២០១៧ កំពុងត្រូវបានព្រះរាជអាជ្ញាពិនិត្យពិចារណា។ ព័ត៌មានលម្អិតមានបង្ហាញជូននៅក្នុងតារាងទី ៧ និងទី ៨។

តារាងទី ៧៖ វឌ្ឍនភាពនៃសំណុំរឿងជួញដូរមនុស្សដែលជនសង្ស័យត្រូវបានឃាត់ខ្លួន

| ឆ្នាំ | សរុប | វឌ្ឍនភាពនៃសំណុំរឿងជួញដូរមនុស្ស | | | |
|---|---|---|---|---|---|
| | | ករណីដែលបានបញ្ជូនទៅកាន់តុលាការ (%) | ករណីដែលពុំត្រូវបានបញ្ជូនទៅកាន់តុលាការ (%) | ករណីដែលកំពុងស្ថិតនៅក្នុងដៃព្រះរាជអាជ្ញានៅឡើយ (%) | ករណីដែលបញ្ជូនត្រឡប់ទៅមន្ត្រីស៊ើបអង្កេតវិញ (%) |
| ២០១៦ | ៤៤៦ | ៤៣៨ (៩៨,២០%) | ៧ (១,៥៧%) | - | ១ (០,២៣%) |
| ២០១៧ | ៣៩៦ | ៣៨៥ (៩៧,២២%) | ១១ (២,៧៨%) | - | - |
| ២០១៨ | ៣៣១ | ២៩៤ (៨៨,៨៣%) | ៣៣ (៩,៩៧%) | - | ៤ (១,២%) |
| ២០១៩ | ៣៤៣ | ២៧៣ (៧៩,៥៩%) | ៦៥ (១៨,៩៥%) | ១ (០,២៩%) | ៥(១,៤៦%) |
| ២០២០ | ២២៥ | ២០១ (៨៩,៣៤%) | ១៦ (៧,១១%) | ២ (០,៨៩%) | ៦ (២,៦៦%) |

តារាងទី ៨៖ វឌ្ឍនភាពនៃសំណុំរឿងជួញដូរមនុស្សដែលជនសង្ស័យបានរត់គេចខ្លួន

| ឆ្នាំ | សរុប | វឌ្ឍនភាពនៃសំណុំរឿងជួញដូរមនុស្ស | | | |
|---|---|---|---|---|---|
| | | ករណីដែលបានបញ្ជូនទៅកាន់តុលាការ (%) | ករណីដែលពុំត្រូវបានបញ្ជូនទៅកាន់តុលាការ (%) | ករណីដែលកំពុងស្ថិតនៅក្នុងដៃព្រះរាជអាជ្ញានៅឡើយ (%) | ករណីដែលបញ្ជូនត្រឡប់ទៅមន្ត្រីស៊ើបអង្កេតវិញ (%) |
| ២០១៦ | ១៩ | ១៦(៨៤,២១%) | ២(១០,៥៣%) | - | ១(៥,២៦%) |
| ២០១៧ | ២២ | ១៦(៧២,៧៣%) | ៤(១៨,១៩%) | ១(៤,៥៤%) | ១ (៤,៥៤%) |
| ២០១៨ | ២៦ | ២៣ (៨៨,៤៦%) | ១ (៣,៨៥%) | - | ២(៧,៦៩%) |
| ២០១៩ | ២១ | ១៧(៨០,៩៥%) | ៣(១៤,២៩%) | ១(៤,៧៦%) | - |
| ២០២០ | ១៦ | ១២(៧៥%) | - | ១(៦,២៥%) | ៣(១៨,៧៥%) |

# សូចនាករទី ៣៖ សំណុំរឿងជួញដូរមនុស្ស ដែលស្ថិតនៅក្នុងដៃតុលាការ

របាយការណ៍ពីចំនួនសំណុំរឿងជួញដូរមនុស្សនៅតុលាការដែលត្រូវបានដាក់ និង បញ្ចប់នីតិវិធីនៅក្នុងឆ្នាំរបាយការណ៍។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

តារាងទី ៩៖ សេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងជួញដូរមនុស្ស

| ឆ្នាំ | សំណុំរឿងដែលបញ្ជូនទៅកាន់តុលាការ | | | ករណីដែលត្រូវបានសម្រេច | | | | សំណុំរឿងដែលកំពុងរងចាំ (នៅមិនទាន់បញ្ចប់នៅឡើយ នៅចុងឆ្នាំដែលបានបង្ហាញនេះ) |
|---|---|---|---|---|---|---|---|---|
| | សំណុំរឿងដែលត្រូវបានដាក់នៅឆ្នាំមុន | សំណុំរឿងដែលត្រូវបានដាក់នៅក្នុងឆ្នាំដែលត្រូវបានបង្ហាញនេះ | សរុប | ផ្តន្ទាទោសឱ្យជាប់ទោស | កាត់ទោសឱ្យរួចខ្លួន | ទម្លាក់ចោលបទចោទ | សរុប | |
| ២០១៦ | ១៣៦ | ៤៦៨ | ៦០៤ | ២៩៨ (៧៩,០៥%) | ៣៧ (៩,៨១%) | ៤២ ( ១១,១៤%) | ៣៧៧ | ២២៧ |
| ២០១៧ | ២២៧ | ៣៣០ | ៥៥៧ | ៣១៩ (៨១,៥៩%) | ៥៤ (១៣,៨១%) | ១៨ (១,៦% ) | ៣៩១ | ១៦៦ |
| ២០១៨ | ១៦៦ | ២៧៩ | ៤៤៥ | ២៣៥ (៧៧,០៥%) | ២៤ (៧,៨៧%) | ៤៦ (១៥,០៨% ) | ៣០៥ | ១៤០ |
| ២០១៩ | ១៤០ | ២៥៦ | ៣៩៦ | ២១៧ (៧៦,៦៨%) | ២៦ (៩,១៩%) | ៤០ (១៤,១៣%) | ២៨៣ | ១១៣ |
| ២០២០ | ១១៣ | ១៩១ | ៣០៤ | ១៥៧ (៧៨,៨៩%) | ២២ (១១,០៦%) | ២០ (១០,០៥%) | ១៩៩ | ១០៥ |

# សូចនាករទី ៤៖ រយៈពេលជាមធ្យមនៃការអនុវត្តនីតិវិធី ចំពោះសំណុំរឿងជួញដូរមនុស្ស

របាយការណ៍ពីរយៈពេលជាមធ្យមនៃចំណាត់ការចំពោះសំណុំរឿងជួញដូរមនុស្សមួយ ចាប់ពីការដាក់ពាក្យបណ្តឹងនៅតុលាការ រហូតដល់ការបញ្ចប់នីតិវិធីក្នុងឆ្នាំរបាយការណ៍។ តួលេខនេះត្រូវបានគណនាដោយបូកសរុបចំនួនថ្ងៃ សម្រាប់សំណុំរឿងនីមួយៗ ចាប់គិតពីកាលបរិច្ឆេទដែលសំណុំរឿងត្រូវបានដាក់ រហូតដល់កាលបរិច្ឆេទបញ្ចប់នីតិវិធី បន្ទាប់មកយកចំនួននេះចែកនឹងចំនួនសំណុំរឿងដែលបញ្ចប់នីតិវិធី។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃបង្ហាញពីចំនួន និងភាគរយនៃសំណុំរឿងនៅតុលាការដែលបានបញ្ចប់នីតិវិធីនៅក្នុងរយៈពេលណាមួយ។ នគរបាល និងព្រះរាជអាជ្ញា បង្ហាញពីរយៈពេលមធ្យម ហើយតុលាការយកព័ត៌មាននេះទៅពិចារណាសម្រាប់ឆ្នាំ ២០២១។**

ដ្យាក្រាមទី ៣៖ រយៈពេលជាមធ្យមដែលមន្រ្តីស្រាវជ្រាវធ្វើការពិចារណាលើសំណុំរឿងជួញដូរមនុស្ស




តារាងទី ១០៖ រយៈពេល ដើម្បីឱ្យតុលាការធ្វើការពិចារណាលើសំណុំរឿងជួញដូរមនុស្ស

| ឆ្នាំ | ចំនួនករណីដែលបានបញ្ចប់ | ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ខែ | ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣-៦ ខែ | ត្រូវបានបញ្ចប់ក្នុងរយៈពេល ៦-១២ ខែ | ត្រូវបានបញ្ចប់ក្នុងរយៈពេល ១២ ខែ |
|---|---|---|---|---|---|
| ២០១៦ | ៣៧៧ | ៨៨ (២៣,៣៤%) | ១០៥ (២៧,៨៥%) | ១៤៦ (៣៨,៧៣%) | ៣៨ (១០,០៨%) |
| ២០១៧ | ៣៩១ | ៩៦ (២៤,៥៥%) | ៩៩ (២៥,៣២%) | ១៥២ (៣៨,៨៧%) | ៤៤ (១១,២៥%) |
| ២០១៨ | ៣០៥ | ៨៦ (២៨,២០%) | ៨០ (២៦,២៣%) | ១២៨ (៤១,៩៧%) | ១១ (៣,៦១%) |

# សូចនាករទី ៥៖ បណ្តឹងឧទ្ធរណ៍ក្នុងករណីជួញដូរមនុស្ស




របាយការណ៍ពីចំនួនបណ្តឹងឧទ្ធរណ៍ក្នុងករណីជួញដូរមនុស្ស ដែលត្រូវបានដាក់ និងបញ្ចប់នីតិវិធីនៅក្នុងឆ្នាំរបាយការណ៍។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**របាយការណ៍ប្រចាំឆ្នាំ ២០២០ របស់តុលាការកំពូលឥណ្ឌូនេស៊ី**

ទិន្នន័យដែលត្រូវបានកត់ត្រានៅក្នុងរយៈពេល ១ ឆ្នាំ

ល្អបំផុតគេត្រូវបញ្ចូលទិន្នន័យបណ្តឹងឧទ្ធរណ៍ ៣ ទៅ ៥ ឆ្នាំ ក្នុងរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស

# សូចនាករទី ៦៖ លទ្ធផលនៃសំណុំរឿង កាត់ឱ្យជាប់ទោស ឬកាត់ឱ្យរួចខ្លួន




របាយការណ៍ពីចំនួនករណីដែលបានបញ្ចប់នីតិវិធី ដែលនាំឱ្យមានការកាត់ទោសឱ្យជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សជាប់ទោស ឬរួចខ្លួន។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

តារាងទី ៩៖ សេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងជួញដូរមនុស្ស

| ឆ្នាំ | សំណុំរឿងដែលត្រូវបានដាក់ទៅកាន់តុលាការ | | | សំណុំរឿងដែលត្រូវបានកាត់សេចក្តី | | | | សំណុំរឿងដែលកំពុងរងចាំ (នៅមិនទាន់បញ្ចប់នៅឡើយ នៅចុងឆ្នាំដែលបានបង្ហាញនេះ) |
|---|---|---|---|---|---|---|---|---|
| | សំណុំរឿងដែលបានដាក់នៅក្នុងឆ្នាំមុន | សំណុំរឿងដែលត្រូវបានដាក់នៅក្នុងឆ្នាំដែលត្រូវបានបង្ហាញនេះ | សរុប | កាត់ឱ្យជាប់ទោស | កាត់ឱ្យរួចខ្លួន | ទម្លាក់ចោល បទចោទ | សរុប | |
| ២០១៦ | ១៣៦ | ៤៦៨ | ៦០៤ | ២៩៨ (៧៩,០៥%) | ៣៧ (៩,៨១%) | ៤២ (១១,១៤%) | ៣៧៧ | ២២៧ |
| ២០១៧ | ២២៧ | ៣៣០ | ៥៥៧ | ៣១៩ (៨១,៥៩%) | ៥៤ (១៣,៨១%) | ១៨ (៤,៦០%) | ៣៩១ | ១៦៦ |
| ២០១៨ | ១៦៦ | ២៧៩ | ៤៤៥ | ២៣៥ (៧៧,០៥%) | ២៤ (៧,៨៧%) | ៤៦ (១៥,០៨% ) | ៣០៥ | ១៤០ |
| ២០១៩ | ១៤០ | ២៥៦ | ៣៩៦ | ២១៧ (៧៦,៦៨%) | ២៦ (៩,១៩%) | ៤០ (១៤,១៣%) | ២៨៣ | ១១៣ |
| ២០២០ | ១១៣ | ១៩១ | ៣០៤ | ១៥៧ (៧៨,៨៩%) | ២២ (១១,០៦%) | ២០ (១០,០៥%) | ១៩៩ | ១០៥ |

៧ លទ្ធផលនៃសំណុំរឿង ចុងចោទត្រូវបានផ្តន្ទាទោស

# សូចនាករទី ៧៖ លទ្ធផលនៃសំណុំរឿង ចុងចោទត្រូវបានផ្តន្ទាទោស ឬកាត់ឱ្យរួចខ្លួន

រាយការណ៍ពីចំនួនចុងចោទដែលត្រូវបានកាត់ឱ្យជាប់ទោស ឬកាត់ឱ្យរួចខ្លួនពីបទល្មើសជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

តារាងទី ១១៖ ចុងចោទក្នុងសំណុំរឿងជួញដូរមនុស្សដែលត្រូវបាននាំខ្លួនឱ្យបង្ហាញមុខក្នុងតុលាការយុត្តិធម៌

| ឆ្នាំ | ចំនួនចុងចោទដែលត្រូវបានតុលាការធ្វើការពិចារណា | | | |
|---|---|---|---|---|
| | សរុប | កាត់ឱ្យជាប់ទោស | កាត់ឱ្យរួចខ្លួន | ទម្លាក់បទចោទ |
| ២០១៦ | ៤៩៣ | ៣៦៦ (៧៤,២៤%) | ៦៩ (១៤%) | ៥៨ (១១,៧៦%) |
| ២០១៧ | ៦៣៨ | ៤៦៦ (៧៣,០៤%) | ១៥៤ (២៤,១៤%) | ១៨ (២,៨២%) |
| ២០១៨ | ៤៣៨ | ៣១៦ (៧២,១៥%) | ៥៧ (១៣,០១%) | ៦៥ (១៤,៨៤%) |
| ២០១៩ | ៣៨៦ | ៣០៤ (៧៨,៧៦%) | ២៧ (៦,៩៩%) | ៥៥ (១៤,២៥%) |
| ២០២០ | ៣០២ | ២៣៣ (៧៧,១៥%) | ៤១ (១៣,៥៨%) | ២៨ (៩,២៧%) |

៨ លទ្ធផលនៃសំណុំរឿង សំណងជំងឺចិត្ត សំណងបដិទាន សំណងជួសជុលការខូចខាត

# សូចនាករទី ៨៖ លទ្ធផលនៃសំណុំរឿង សំណងជំងឺចិត្ត សំណងបដិទាន សំណងជួសជុលការខូចខាត

រាយការណ៍ពីចំនួន និងភាគរយនៃសំណុំរឿងជួញដូរមនុស្ស ដែលត្រូវបានបញ្ចប់នីតិវិធីដែលក្នុងនោះតុលាការបញ្ជាឱ្យផ្តល់សំណងជំងឺចិត្ត / សំណងបដិទាន / សំណងជួសជុលការខូចខាត់ដល់ជនរងគ្រោះ។

ពុំមានឧទាហរណ៍ពីប្រទេសជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP ឡើយ

# សូចនាករទី ៩៖ លទ្ធផលនៃសំណុំរឿង សំណងជំងឺចិត្ត សំណងបជិទាន សំណងជួសជុលការខូចខាត ដែលជនរងគ្រោះបានទទួល




របាយការណ៍ពីចំនួន និងភាគរយសំណុំរឿងជួញដូរមនុស្សដែលបានបញ្ចប់នីតិវិធី ដែលក្នុងនោះជនរងគ្រោះបានទទួលសំណងជំងឺចិត្តពីមូលនិធិជាតិផ្តល់សំណង ឬសំណងបជិទាន / សំណងជួសជុលការខូចខាតពីជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ស្តីពីការជួញដូរមនុស្សរយៈពេល ៥ ឆ្នាំរបស់ឥណ្ឌូនេស៊ី**

**៥. ជនរងគ្រោះសរុបដែលបានទទួលសំណងបជិទាន**

ស្ថាប័ន LPSK បានជួយសម្រួលដល់ការគណនា និងការផ្តល់សំណងបជិទានដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងអស់ក្នុងកម្មវិធីផ្តល់ការការពារដល់ជនរងគ្រោះ ដែលត្រូវបានអនុវត្តពីឆ្នាំ ២០១៥-២០១៩។ កម្មវិធីនេះបានជួយផ្តល់ការសម្របសម្រួល ត្បិតដំណើរការនីតិវិធីច្បាប់សម្រាប់ជនរងគ្រោះ ធ្វើឡើងជាការស្រាវជ្រាវផ្នែកច្បាប់ និង/ឬការស៊ើបអង្កេត ប្រសិនបើការការពារដំបូងដែលផ្តល់ដោយស្ថាប័ននេះអាចផ្តល់ឱ្យបាននៅកម្រិតនេះ។ ស្ថាប័ននេះបានជួយផ្តល់ការសម្របសម្រួលបន្ថែមទៀត ក្នុងអំឡុងការអនុវត្តនីតិវិធីនៅដំណាក់កាលអយ្យការ និងការពិនិត្យលើសំណុំរឿងមុនការអនុវត្តនីតិវិធីរបស់តុលាការ។ ក្នុងករណីមួយចំនួន ជនរងគ្រោះដោយអំពើជួញដូរមនុស្សមានបំណងមិនចង់ដាក់ពាក្យ ដើម្បីស្នើសុំសំណងបជិទាន ឧទាហរណ៍នៅពេលដែលជនរងគ្រោះប៉ាន់ស្មានដឹង ឬដឹងថាជនមុខសញ្ញាពុំមានលទ្ធភាពបង់សំណងបជិទាន។ ក្នុងករណីនេះ ស្ថាប័ននេះមិនធ្វើការសម្របសម្រួលជួយគណនា និងស្នើសុំសំណងបជិទានឡើយ។

បើតាមស្ថាប័ន LPSK ក្នុងរយៈពេលពីឆ្នាំ ២០១៥ ដល់ ២០១៩ ស្ថាប័ននេះបានផ្តល់ឱ្យជនរងគ្រោះ ដែលបានទទួលការការពារចំនួន ១.១៦៥ នាក់នៅសេវាចំនួន ៩៦៣ លើក (៨២,៦៦%) ដែលក្នុងនោះ ២៣៤ ករណី (១០០) ក្នុងឆ្នាំ ២០១៥, ១៤៨ ករណី (៨៧,៦០) ក្នុងឆ្នាំ ២០១៦, ២២៦ ករណី (៨៧,៩៤%) ក្នុងឆ្នាំ ២០១៧, ១៣១ ករណី (៧០,៤៣%) ក្នុងឆ្នាំ ២០១៨ និង ២២៤ ករណី (៧០,៤៤%) ក្នុងឆ្នាំ ២០១៩។

តារាង ៣៣៖ ចំនួនជនរងគ្រោះសរុបដែលបានទទួលសំណងបជិទានតាមរយៈកម្មវិធីការពារសាក្សី ឬជនរងគ្រោះ ដែលអនុវត្តដោយ LPSK

| ចំនួន | ឆ្នាំ | បានទទួលការការពារ | បជិទាន | |
|---|---|---|---|---|
| | | Σ | Σ | % |
| (១) | (២) | (៣) | (៤) | (៤) |
| ១ | ២០១៥ | ២៣៤ | ២៣៤ | ១០០ |
| ២ | ២០១៦ | ១៧០ | ១៤៨ | ៨៧.០៦ |
| ៣ | ២០១៧ | ២៥៧ | ២២៦ | ៨៧.៩៤ |
| ៤ | ២០១៨ | ១៨៦ | ១៣១ | ៧០.៤៣ |
| ៥ | ២០១៩ | ៣១៨ | ២២៤ | ៧០.៤៤ |
| សរុប | | ១១៦៥ | ៩៦៣ | ៨២.៦៦ |

*ប្រភព៖* LPSK. ២០២០

# សូចនាករទី ១០៖ ការគាំទ្រដល់ជនរងគ្រោះ ជំនួយផ្លូវច្បាប់




របាយការណ៍ពីចំនួន និងភាគរយសំណុំរឿងជួញដូរមនុស្សដែលត្រូវបានដាក់ ហើយដែលជនរងគ្រោះបានទទួលសេវាជំនួយផ្លូវច្បាប់។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ស្តីពីការជួញដូរមនុស្សរយៈពេល ៥ ឆ្នាំរបស់ឥណ្ឌូនេស៊ី និងគេហទំព័ររបស់ LPSK**




តារាង ៣១៖ ចំនួនសេវាសរុបដែលផ្តល់ដោយ LPSK តាមរយៈកម្មវិធីការងារសាក្សី និង/ឬជនរងគ្រោះដោយអំពើជួញដូរមនុស្ស

| ចំនួន | ឆ្នាំ | ប្រភេទ និងចំនួនសេវាសរុប | | | | | | | | | | | | | | សេវាសរុប | % |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | PHP | | ផ្លូវកាយ | | វេជ្ជសាស្ត្រ | | ផ្លូវចិត្ត | | ចិត្តសង្គម | | សំណងបជិទាន | | សំណងជំងឺចិត្ត | | | |
| | | Σ | % | Σ | % | Σ | % | Σ | % | Σ | % | Σ | % | Σ | % | | |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) |
| ១ | ២០១៥ | ១០៨ | ២៦.០៩ | ៤៧ | ១១.៣៥ | ១២ | ២.៩០ | ១៣ | ៣.១៤ | 0 | 0.00 | ២៣៤ | ៥៦.៥២ | 0 | 0.00 | ៤១៤ | ១០០ |
| ២ | ២០១៦ | ១៧០ | ៥០.០០ | ៧ | ២.០៦ | ៧ | ២.០៦ | ៥ | ១.៤៧ | ៣ | 0.៨៨ | ១៤៨ | ៤៣.៥៣ | 0 | 0.00 | ៣៤០ | ១០០ |
| ៣ | ២០១៧ | ២៥៤ | ៤៧.៨៣ | ១០ | ១.៨៨ | ២២ | ៤.១៤ | ១៦ | ៣.០១ | ៣ | 0.៥៦ | ២២៦ | ៤២.៥៦ | 0 | 0.00 | ៥៣១ | ១០០ |
| ៤ | ២០១៨ | ១៧៥ | ៥២.៧១ | ៥ | ១.៥១ | ១០ | ៣.០១ | ១០ | ៣.០១ | ១ | 0.៣០ | ១៣១ | ៣៩.៤៦ | 0 | 0.00 | ៣៣២ | ១០០ |
| ៥ | ២០១៩ | ២៦៩ | ៤៧.០៣ | ១៨ | ៣.១៥ | ១៦ | ២.៨០ | ២៤ | ៤.២០ | ២១ | ៣.៦៧ | ២២៤ | ៣៩.១៦ | 0 | 0.00 | ៥៧២ | ១០០ |
| សរុប | | ៩៧៦ | ៤៤.៥៩ | ៨៧ | ៣.៩៧ | ៦៧ | ៣.០៦ | ៦៨ | ៣.១១ | ២៨ | ១.២៨ | ៩៦៣ | ៤៣.៩៩ | 0 | 0.00 | ២១៨៩ | ១០០ |

យោបល់៖

- PHP៖ ការផ្តល់សិទ្ធិទៅតាមនីតិវិធី (Fulfillment of the Procedural Rights)
- ផ្លូវកាយ៖ ការការពារផ្លូវកាយ

*ប្រភព៖* LPSK. ២០២០

# សូចនាករទី ១១៖ ការគាំទ្រដល់ជនរងគ្រោះ - ការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូជាមុន

រាយការណ៍ពីចំនួន និងភាគរយនៃសំណុំរឿងជួញដូរមនុស្ស ដែលត្រូវបានដាក់ទៅកាន់តុលាការ ដែលជនរងគ្រោះអាចផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូមុននីតិវិធីសវនាការ។

១១ ការគាំទ្រដល់ជនរងគ្រោះ - ការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូ

ឧទាហរណ៍ពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ**

**៦) ការប្រើប្រាស់សវនាការជាមួយសាក្សីជាមុន/សវនាការដែលសាក្សី និងចុងចោទមិនប្រឈមមុខដាក់គ្នាក្នុងសំណុំរឿងជួញដូរមនុស្ស**

ការិយាល័យតុលាការបន្តរៀបចំប្រព័ន្ធវីដេអូ Conference សម្រាប់គ្រប់បន្ទប់ទាំងអស់នៅក្នុងតុលាការទូទាំងប្រទេស ដើម្បីផ្តល់លទ្ធភាពឱ្យមានការរៀបចំសវនាការក្នុងសំណុំរឿងជួញដូរមនុស្ស ដោយពុំមានប្រឈមមុខដាក់គ្នា។ ចៅក្រមត្រូវបានប្រាប់ឱ្យអនុញ្ញាតឱ្យមានការធ្វើសវនាការទុកជាមុន ឬការធ្វើសវនាការដោយពុំមានការប្រឈមមុខដាក់គ្នា នៅពេលដែលមានការស្នើសុំ ឬក្នុងករណីដែលសមស្រប។ ក្នុងករណីចាំបាច់ ឬករណីប្រធានស័ក្តិ ជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចធ្វើសក្ខីកម្មរបស់ខ្លួន តែអាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺជាផ្នែកមួយនៃគោលនយោបាយ ដើម្បីជំរុញឱ្យមានការប្រើប្រាស់អភិក្រមយកចិត្តទុកដាក់ចំពោះជនរងគ្រោះកាន់តែច្រើន ក្នុងដំណើរការចោទប្រកាន់ និងផ្តន្ទាទោសក្នុងសំណុំរឿងជួញដូរមនុស្ស និងបានជួយធានាថាជនរងគ្រោះនឹងមិនទទួលរងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ក្នុងអំឡុងពេលដែលពួកគេចូលរួមក្នុងនីតិវិធីជំនុំជម្រះនោះឡើយ។

ព័ត៌មានលម្អិតអំពីសវនាការទុកជាមុនរបស់សាក្សី ដែលតុលាការអនុញ្ញាតឱ្យរៀបចំក្នុងសំណុំរឿងជួញដូរមនុស្ស ចាប់តាំងពីឆ្នាំ ២០១៨ មក មានបង្ហាញនៅក្នុងតារាងទី ១៤។ ការថយចុះនៃចំនួនការរៀបចំសវនាការទុកជាមុននៅក្នុងឆ្នាំ ២០២០ អាចដោយសារស្ថានការណ៍ជំងឺកូវីដ ១៩ និងដោយសារការថយចុះនៃចំនួនសំណុំរឿងដែលត្រូវបានដាក់ បើធៀបនឹងឆ្នាំមុនៗ។

តារាងទី ១៤៖ សវនាការទុកជាមុនរបស់សាក្សី ដែលរៀបចំដោយតុលាការក្នុងសំណុំរឿងជួញដូរមនុស្ស

| ឆ្នាំ | ចំនួនសំណុំរឿង | ចំនួនសវនាការដែលរៀបចំទុកជាមុន | ចំនួនសាក្សី |
|---|---|---|---|
| ២០១៨ | ២៨៣ | ៣៣ | ៧៥ |
| ២០១៩ | ២៤៩ | ៣៦ | ១៣១ |
| ២០២០ | ១៩០ | ១១ | ៦៧ |

*សម្គាល់ទិន្នន័យនៅក្នុងកូឡោនទី ៣ នៃតារាងនេះ សំដៅលើ "ចំនួនសំណុំរឿងដែលសាក្សីផ្តល់កស្តុតាង តាមរយៈសវនាការដែលរៀបចំទុកជាមុន" មិនមែនជា "ចំនួននៃការរៀបចំសវនាការទុកជាមុននោះឡើយ"*

# សូចនាករទី ១២៖ ការគាំទ្រដល់ជនរងគ្រោះ - យន្តការដាក់ពាក្យបណ្តឹងជាសាធារណៈ

រាល់ព័ត៌មានអំពីដំណើរការទទួលពាក្យបណ្តឹង និងធ្វើចំណាត់ការលើពាក្យបណ្តឹងអំពីការជួញដូរមនុស្ស ដែលមានជាសាធារណៈ។

១២ ការគាំទ្រដល់ជនរងគ្រោះ - យន្តការដាក់ពាក្យបណ្តឹងជាសាធារណៈ

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**គេហទំព័រតុលាការកំពូលឥណ្ឌូនេស៊ី**



# សូចនាករទី ១៣៖ ទិន្នន័យអំពីប្រភេទអំពើជួញដូរមនុស្ស

របាយការណ៍ពីចំនួនករណីជួញដូរមនុស្សបែងចែកទៅតាមប្រភេទផ្សេងៗនៃការជួញដូរមនុស្ស។

១៣ ទិន្នន័យអំពីប្រភេទអំពើជួញដូរមនុស្ស

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីការជួញដូរមនុស្សរបស់ប្រទេសកម្ពុជា**

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| - ការនាំអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០៥ | ០៦ | ០៥ | |
| - ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៦ | ០៣៣ | ០៥ | |
| - ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០៣ | ០១៨ | ០៥ | បង់ក្លាដេស០១ |
| - ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២២ | ១៦២ | ២៩ | |
| - អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០១ | |
| - អំពើនាំឆ្លងព្រំដែន | ០១ | -៣៧ | ០១ | ស៊ុយអ៊ែត០១ |
| - ការទទួលមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០០ | ០២ | អាមេរិក០១ |
| - ការទិញពេស្យាចារកុមារ | ០៥ | ០៩ | ០៦ | អ៊ីស្រាអ៊ែល០១ |
| **សរុប** | **៤៤ ករណី** | **២៧៦ នាក់** | **៥៥ នាក់** | **០៤ នាក់** |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១១១ ករណី / ១៣១ ករណី(ថយចុះ ២០ ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៣៨ / ១៦៨ នាក់ (ស្រី ១៣ នាក់) អនីតិជន ១២ នាក់ ជនបរទេស ១៩ នាក់ មាន ០៤ សញ្ជាតិ ។ សង្គ្រោះជនរងគ្រោះ ចំនួន ១៩១ / ៣០៥ នាក់ មាន៖ អាយុក្រោម ១៥ ឆ្នាំ ៩៩ នាក់ អាយុ ១៥-១៧ ឆ្នាំ ២៣នាក់ និងអាយុពី ១៨ ឆ្នាំឡើង ៦៩ នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ៦៨ នាក់ និងប្រគល់ឱ្យ គ្រួសារ ១២៣ នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| - សញ្ចារកម្ម | ៦ | ៣៥ | ១២ | ចិន ៤ រុស្ស៊ី ១ |
| - ស្ពានទម្ងន់ទោសនៃសញ្ចារកម្ម | ៤ | ២៥ | ១០ | |
| - សញ្ចារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ) | ២ | ១៩ | ៣ | វៀតណាម៤ |
| - បទល្មើសទាក់ទងនឹងពស្យាចារកុមារ | ១ | ៦ | ២ | |
| - ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ១ | ១ | ៩ | |
| - ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ១ | ៤ | ១ | |
| - រូបភាព និងសម្ភារៈអាសអាភាស | ៥ | ៦ | ៨ | ចិន៩ |
| - រូបភាព និងសម្ភារៈអាសអាភាសនកុមារ | ៣ | ៣ | ៣ | |
| - អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៧១ | ៧២ | ៧៣ (អនីតិជន ១២) | |
| - -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៧ | ២០ | ១៧ | អង់គ្លេស១ |
| **សរុប** | **១១១ ករណី** | **១៩១ នាក់** | **១៣៨ នាក់ (អនីតិជន១២)** | **១៩ នាក់** |

# សូចនាករទី ១៤៖ ទិន្នន័យបែងចែកតាមភេទ

របាយការណ៍ពីចំនួនសំណុំរឿងជួញដូរមនុស្សបែងចែកតាមប្រភេទនៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

១៤ ទិន្នន័យបែងចែកតាមភេទ

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ការជួញដូរមនុស្សរយៈពេល ៥ ឆ្នាំរបស់ឥណ្ឌូនេស៊ី**

តារាងទី ៣៖ ការបែងចែកចំនួនរបាយការណ៍ប៉ូលីស




| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| ■ Perempuan Dewasa | ១២៣ | ១៨៤ | ១៣៥០ | ១៩០ | ២០០ |
| ■ Anak Perempuan | ៧០ | ៦៧ | ៨៩ | ១៨ | ២៨ |
| ■ Laki-laki Dewasa | ៩៥ | ៨១ | ១១ | ៧៩ | ៥២ |
| ■ Anak Laki-laki | ០ | ០ | ១ | ១០ | ០ |

*ប្រភព៖* បញ្ចូលរបាយការណ៍ប៉ូលីសខេត្ត និង CID-INP ២០១៩

# សូចនាករទី ១៥៖ ទិន្នន័យបែងចែកតាមអាយុ

## របាយការណ៍ពីចំនួនករណីជួញដូរមនុស្សបែងចែកតាមអាយុរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ ចំនួនជនរងគ្រោះជាកុមារ និងចំនួនជនរងគ្រោះជាមនុស្សពេញវ័យ

១៥ ទិន្នន័យបែងចែកតាមអាយុ

ឧទាហរណ៍ពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់ប្រទេសថៃ ឆ្នាំ ២០២០**

ដ្យាក្រាមទី ២៖ សង្ខេបករណីជនសង្ស័យ និងជនរងគ្រោះក្នុងឆ្នាំ ២០២០




# សូចនាករទី ១៦៖ ទិន្នន័យបែងចែកតាមពិការភាព

## របាយការណ៍ពីចំនួនករណីជួញដូរមនុស្សបែងចែកពិការភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

១៦ ទិន្នន័យបែងចែកតាមពិការភាព

ពុំមានឧទាហរណ៍ពីប្រទេសជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP ឡើយ

សំណួមពរ៖

បង្ហាញទិន្នន័យដោយប្រើប្រាស់សំណួរក្រុមវ៉ាស៊ីងតោន ដែលត្រូវបានប្រើប្រាស់ជាសកលក្នុងទិន្នន័យជំរឿន និងទិន្នន័យដែលប្រមូលដោយការិយាល័យស្ថិតិជាទៀត៖

តើអ្នកពិបាកក្នុងការមើលដែរឬទេ?
តើអ្នកពិបាកក្នុងការស្តាប់ដែរឬទេ?
តើអ្នកពិបាកក្នុងការដើរ ឬផ្លាស់ទីដែរឬទេ?
តើអ្នកពិបាកក្នុងការយល់ ឬផ្ចង់អារម្មណ៍ដែរឬទេ?
តើអ្នកមានការពិបាក ដើម្បីឱ្យមនុស្សដទៃទៀតយល់ពីអ្នកដែរឬទេ?

# សូចនាករទី ១៧៖ របាយការប្រចាំឆ្នាំស្តីពីករណីជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ




ប្រទេសដែលផលិត ឬរួមចំណែកដល់ការរៀបចំរបាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំដែលអាចរកបានជាសាធារណៈ។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន និងថៃ**




# សូចនាករទី ១៨៖ របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ៖ ទិន្នន័យនិន្នាការ ៣ ទៅ ៥ ឆ្នាំ




របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ បង្ហាញទិន្នន័យនិន្នាការ ៣ ទៅ ៥ ឆ្នាំ ដោយប្រើប្រាស់សំណុំទិន្នន័យសំខាន់ៗស្តីពីការជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**របាយការណ៍ស្តីពីការជួញដូរមនុស្សរយៈពេល ៥ ឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ី**

តារាងទី ៤៖ សំណុំរឿងជួញដូរមនុស្សបែងចែកតាម MODES




| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| ▪ ពលករទេសន្តរប្រវេសក៍ | ៤៧ | ៤៣ | ៣៥ | ៤៧ | ៥០ |
| ▪ អ្នកប្រកបរបរផ្លូវភេទ | ៧១ | ៦០ | ៧៨ | ៣៨ | ៥០ |
| ▪ អ្នកធ្វើការតាមផ្ទះ | ១ | ៤ | ៨ | ៨ | ២ |
| ▪ នាវិក | ២ | ០ | ១ | ០ | ១ |
| ▪ ជួញដូរសរីរាង្គ | ០ | ១ | ០ | ០ | ០ |
| ▪ ជួញដូរកុមារ | ២ | ២ | ១ | ២ | ០ |

*ប្រភព៖* បញ្ចូលរបាយការណ៍ប៉ូលីសខេត្ត និង CID-INP បញ្ចូលគ្នា ឆ្នាំ ២០១៩

## សូចនាករទី ១៩៖ របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ៖ កិច្ចសហការនៅថ្នាក់ជាតិ និងថ្នាក់តំបន់




របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស បង្ហាញពីសកម្មភាព/កិច្ចប្រជុំពាក់ព័ន្ធនឹងករណីជួញដូរមនុស្សរវាងដៃគូរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ក៏ដូចជាអង្គការជាដៃគូនៅថ្នាក់តំបន់ដែលធ្វើការងារពាក់ព័ន្ធនឹងការជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន និងថៃ**

## សូចនាករទី ២០៖ របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស៖ មន្ត្រីដែលសមគំនិត




របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស បង្ហាញពីចំនួនការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសមន្ត្រីដែលសមគំនិតប្រព្រឹត្តអំពើជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖

**របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ ២០២០ របស់ប្រទេសថៃ**

តារាងទី ១៦៖ មន្ត្រីសាធារណៈដែលសង្ស័យថាបានសមគំនិតក្នុងសំណុំរឿងជួញដូរមនុស្ស បែងចែកតាមប្រភេទ

| ឆ្នាំ | ចំនួនមន្ត្រីសាធារណៈ | ប្រភេទមន្ត្រីសាធារណៈ | | | | |
|---|---|---|---|---|---|---|
| | | មន្ត្រីប៉ូលីស | មន្ត្រីយោធា | មន្ត្រីរាជការ/គ្រូបង្រៀន | មន្ត្រីរដ្ឋបាលមូលដ្ឋាន | ព្រះរាជអាជ្ញា |
| ២០១២-១៦ | ៤៥ | ២៣ | ៨ | ២ | ១២ | - |
| ២០១៧ | ១១ | ៨ | - | ១ | ២ | - |
| ២០១៨ | ២ | ២ | - | - | - | - |
| ២០១៩ | ៧ | ៦ | - | - | - | - |
| ២០២០ | ៩ | ៥ | - | ២ | - | ២ |
| សរុប | ៧៤ | ៤៥ | ៨ | ៥ | ១៤ | ២ |

ចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២០ មានមន្ត្រីសាធារណៈសរុបចំនួន ៧២ នាក់បានទទួលការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ក្នុងឆ្នាំ ២០២០ ក្នុងចំណោមមន្ត្រីសាធារណៈជាជនសង្ស័យចំនួន ៩ នាក់ RTP និង DSI បានបញ្ចប់ការស៊ើបអង្កេតលើមនុស្សចំនួន ៨ នាក់។ មន្ត្រីទាំងនោះ រួមមានមន្ត្រី ២ នាក់ ដែលមន្ត្រីស៊ើបអង្កេត និងព្រះរាជអាជ្ញារកបានភស្តុតាង ដើម្បីចោទប្រកាន់ពីបទចូលរួមពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ ឥឡូវករណីរបស់ពួកគេ កំពុងស្ថិតនៅក្នុងដៃតុលាការដំបូង។

# សូចនាករទី ២១៖ ទីតាំងផ្តល់ព័ត៌មានអំពីសេវាគាំទ្រ និងផ្តល់ជំនួយសម្រាប់ករណីជួញដូរមនុស្ស




កន្លែងច្រកចេញចូលតែមួយ ដើម្បីផ្តល់ព័ត៌មានពីសេវាគាំទ្រ និងជំនួយសម្រាប់ករណីជួញដូរមនុស្ស មានជាសាធារណៈសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ ២០២០ របស់ប្រទេសហ្វីលីពីន**

**ង. ការអនុវត្តបណ្តាញ ACTIONLINE របស់ IACAT ១៣៤៣**

បណ្តាញ Actionline IACAT ១៣៤៣ គឺជាខ្សែទូរស័ព្ទហតឡាញដំបូងសម្រាប់ប្រឆាំងនឹងអំពើជួញដូរមនុស្ស និងករណីដែលពាក់ព័ន្ធដទៃទៀត។ មុខងារចម្បងនៃខ្សែទូរស័ព្ទហតឡាញនេះ គឺដើម្បីទទួល និងឆ្លើយតបជាបន្ទាន់ចំពោះសំណើសុំជំនួយនានា សំណួរ និងការបញ្ជូនរបស់ជនរងគ្រោះ គ្រួសាររបស់ពួកគេ និងសាធារណៈជនទូទៅពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ សេវានេះត្រូវបានពង្រីកបន្ថែម ដើម្បីទទួលយកការរាយការណ៍តាមប្រព័ន្ធអនឡាញ និងសារជាអក្សរ។ ក្នុងឆ្នាំ ២០២០ ខ្សែទូរស័ព្ទ Actionline របស់ IACAT ១៣៤៣ បានទទួលការរាយការណ៍ចំនួន ៥៥ ករណីពាក់ព័ន្ធនឹងជនរងគ្រោះ ដែលត្រូវបានកំណត់អត្តសញ្ញាណចំនួន ៣១ នាក់។

| ឆ្នាំ | ចំនួននៃការហៅទូរស័ព្ទដែល Actionline បានទទួល | ចំនួនការរាយការណ៍ជាក់ស្តែងដែលបានទទួលតាមរយៈការហៅទូរស័ព្ទ និងវិធីសាស្ត្រដទៃទៀត | ចំនួនជនរងគ្រោះ |
|---|---|---|---|
| ២០១១ | ៧.១៧៧ | ៦៩ | ៦៤ |
| ២០១២ | ៧.៧៦២ | ១២៧ | ៩៥ |
| ២០១៣ | ៤.២៦៥ | ៦៧ | ៦០ |
| ២០១៤ | ៤.២២១ | ៧៥ | ៧២ |
| ២០១៥ | ២.៨៦៣ | ៨២ | ១០៨ |
| ២០១៦ | ៣.៧៣១ | ៧៤ | ៦៤ |
| ២០១៧ | ៤.៤៨៣ | ៥៩ | ៦១ |
| ២០១៨ | ៤.៥១០ | ៥៣ | ៣១ |
| ២០១៩ | ៤.២៤៣ | ៤១ | ៣១ |
| **២០២០** | **៤.០៧៥** | **៥៥** | **៣១** |
| សរុប | ៤៧.៣៣០ | ៧០២ | ៦១៧ |

# សូចនាករទី ២២៖ សេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងជួញដូរមនុស្សដែលពុំមានការបង្ហាញពីអត្តសញ្ញាណ និងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ




រាយការណ៍ពីចំនួន និងភាគរយនៃសេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងជួញដូរមនុស្សដែលពុំមានការបង្ហាញពីអត្តសញ្ញាណ និងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ។

ឧទាហរណ៍ល្អពីរដ្ឋជាសមាជិកអាស៊ានដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញា ACTIP៖
**បញ្ជីព័ត៌មានអំពីសំណុំរឿងនៅក្នុងដៃតុលាការកំពូលឥណ្ឌូនេស៊ី**



# ឧបសម្ព័ន្ធទី ២

ទម្រង់សំខាន់ៗ សម្រាប់សូចនាករសមិទ្ធកម្ម
ទិន្នន័យសំខាន់ៗ អំពីការជួញដូរមនុស្សទាំង
២២



ដើម្បីដោនឡូតទម្រង់គំរូជាឧទាហរណ៍ សូមចូលមកគេហទំព័រ https://bit.ly/៣HkBJNV

## Report the number of TIP Court Cases Filed and Finalised in the reporting

**First Instance Courts**

| Year | Cases Submitted to the Courts | | | Decided Cases | | | | Pending Cases |
|---|---|---|---|---|---|---|---|---|
| | Cases pending from previous years | Cases Initiated in reporting year | Total Cases | Convicted | Acquitted | Other | Total | |
| **2017** | | | | | | | | |
| **2018** | | | | | | | | |
| **2019** | | | | | | | | |
| **2020** | | | | | | | | |
| **2021** | | | | | | | | |

**Appeal Courts**

| Year | Cases Submitted to the Courts | | | Decided Cases | | | | Pending Cases |
|---|---|---|---|---|---|---|---|---|
| | Cases pending from previous years | Cases Initiated in reporting year | Total Cases | Convicted | Acquitted | Other | Total | |
| **2017** | | | | | | | | |
| **2018** | | | | | | | | |
| **2019** | | | | | | | | |
| **2020** | | | | | | | | |
| **2021** | | | | | | | | |